**BBI0095**

# សម្ភាសន៍ជាមួយឈ្មោះ ទិត អ៊ីម ភេទស្រី អាយុ៥០ឆ្នាំ

**មុខងារនៅសម័យខ្មែរក្រហមៈ កងចល័ត**

**មុខងារបច្ចុប្បន្នៈ កសិករ**

**ស្រុកកំណើតនៅភូមិធ្លកជូនសុខ ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ**

**សព្វថ្ងៃរស់នៅភូមិពេជ្រចិន្តា ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក្ស ខេត្តបាត់ដំបង**

**ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០០:៣១:៥២**

**១៩ទំព័រ**

ដានី : ចឹងមីងជំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង ។ មីងឈ្មោះពេញឈ្មោះអីដែរ?

អ៊ីម : ឈ្មោះ ទិត អ៊ីម ។

ដានី : ទិត អ៊ីម អាយុប៉ុន្មានហើយ?

អ៊ីម : អាយុ៥០ឆ្នាំ ។

ដានី : ៥០ឆ្នាំគត់?

អ៊ីម : ចា៎!

ដានី : មីងស្រុកកំណើតកើតជានៅភូមិឃុំអីដែរ កំពង់ស្ពឺ?

អ៊ីម : នៅអីឃុំក្រាំងអំពិល ។

ដានី : ក្រាំងអំពិល?

អ៊ីម : ចា៎!

ដានី : ភូមិអីនឹង?

អ៊ីម : ឃុំក្រាំងអំពិល ស្រុកសំរោងទង ។

ដានី : ឃុំក្រាំងអំពិលដែរ?

អ៊ីម : ចា៎!

ដានី : ភូមិក៏ក្រាំងអំពិល?

អ៊ីម : អត់ទេ ភូមិធ្លកជូនសុខ ។

ដានី : ភូមិធ្លកជូនសុខ ក្រាំងអំពិល ស្រុកសំរោងទង?

អ៊ុម : ចា៎! ស្រុកសំរោងទង។

ដានី : កំពង់ស្ពឺ។ សព្វថ្ងៃ មីងនៅភូមិអីឃុំអីដែរ សព្វថ្ងៃនឹង?

អ៊ុម : នៅភូមិពេជ្រចិន្តា ឃុំពេជ្រចិន្តា។

ដានី : ស្រុក?

អ៊ុម : ស្រុកភ្នំព្រឹក្ស។

ដានី : ភ្នំព្រឹក្ស ខេត្តបាត់ដំបង។ មីងគ្រួសារមីង ប្តីមីងគាត់ឈ្មោះអីដែរ?

អ៊ុម : ឈ្មោះ សុខ សំណាង។

ដានី : គាត់អាយុប៉ុន្មានដែរ?

អ៊ុម : គាត់អាយុ៤៥ឆ្នាំ។

ដានី : គាត់អ្នកស្រុកណាដែរ?

អ៊ុម : គាត់ខេត្តកំពង់ស្ពឺដែរ តែស្រុកភ្នំស្រួច។

ដានី : នៅភ្នំស្រួច?

អ៊ុម : ចា៎! ខេត្តកំពង់ស្ពឺ ស្រុកភ្នំស្រួច។

ដានី : មីងមានកូនចៅប៉ុន្មាននាក់?

អ៊ុម : ខ្ញុំកូន៣នាក់។

ដានី : ៣នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

អ៊ុម : ស្រី២ ប្រុស១។

ដានី : សព្វថ្ងៃមីងប្រកបរកស៊ីធ្វើស្អីដែរ?

អ៊ុម : ធ្វើចំការ ហើយស្រែតិចតួច គ្រាន់ហូប។

ដានី : ធ្វើចំការៗធ្វើអីខ្លះទៅ?

អ៊ុម : ចំការ ដាំតែដំឡូង ហើយនឹងសណ្តែកបាយ។

ដានី : ហើយនឹងធ្វើស្រូវៗដាំច្រើន?

អ៊ុម : ស្រូវបាន៨រ៉ៃវា។

ដានី : ម៉ាហិចតាជាង?

អ៊ុម : ចា៎!

ដានី : ហូបគ្រប់គ្រាន់ដែរស្រូវ?

អ៊ុម : ហូបអត់អស់។

ដានី :	ចុះពូគ្រួសារមីងគាត់ធ្វើអីទៅ?

អ៊ីម :	គាត់រត់ឡានតាក់ស៊ី ។

ដានី :	គាត់រត់ឡានតាក់ស៊ី?

អ៊ីម :	ចា៎! ពីកាប៊ីនទៅបាត់ដំបង ។

ដានី :	រត់ឡានតាក់ស៊ីពីណាទៅណា?

អ៊ីម :	ចា៎!

ដានី :	ចឹងធ្វើចំការ តែមីងម្នាក់ឯង?

អ៊ីម :	ចា៎! ធ្វើតែខ្ញុំម្នាក់ឯង ។

ដានី :	គាត់រត់តាមផ្លូវណា ពីនឹងទៅចេះ?

អ៊ីម :	ផ្លូវជួនកាលទៅខ្មែម ជួនកាលទៅត្រង់ចេះ ។

ដានី :	គាត់មកវិលល្ងាច?

អ៊ីម :	វិល គាត់មកវិលល្ងាច ។

ដានី :	គាត់មកផ្ទះរាល់ថ្ងៃ?

អ៊ីម :	ចា៎! មកផ្ទះរាល់ថ្ងៃ ។

ដានី :	ចុះមីងឪពុកម្ដាយមីង គាត់នៅទេសព្វថ្ងៃ?

អ៊ីម :	ឪពុកខ្ញុំគាត់ស្លាប់ហើយ នៅតែម្ដាយ ។

ដានី :	ឪពុកមីងគាត់ឈ្មោះអីទៅ?

អ៊ីម :	ឈ្មោះ ប៉ាត់ តែអត់ស្គាល់ត្រកូលគាត់ ។

ដានី :	ឈ្មោះ ប៉ាត់?

អ៊ីម :	ចា៎!

ដានី :	គាត់ស្លាប់តាំងពីអង្កាល់?

អ៊ីម :	ស្លាប់តាំងពីឆ្នាំ៨៣ ។

ដានី :	៨៣ គាត់ស្លាប់ដោយសារមូលហេតុអី?

អ៊ីម :	គាត់ខ្យល់ ។

ដានី :	គាត់ខ្យល់ ឈឺ?

អ៊ីម :	ចា៎!

ដានី :	ចុះម្ដាយមីងគាត់ឈ្មោះអីដែរ?

អ៊ីម : ម្តាយខ្ញុំឈ្មោះ វ៉ែន ។

ដានី : ឈ្មោះវ៉ែន?

អ៊ីម : ចា៎!

ដានី : គាត់សព្វថ្ងៃ គាត់រស់នៅណា?

អ៊ីម : គាត់នៅ រស់នៅខេត្តកំពង់ស្ពឺនឹង នៅភូមិ ។

ដានី : នៅភូមិកំណើត?

អ៊ីម : នៅភូមិធ្លុកដូនសុខ ។

ដានី : មីងមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់?

អ៊ីម : ៣នាក់ ។

ដានី : បងប្អូន៣នាក់ ។ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

អ៊ីម : ស្រី២ ប្រុស១ ។

ដានី : ស្រី២ ប្រុសមួយដូចមីងដែរ?

អ៊ីម : ចា៎!

ដានី : មីងកូនទីប៉ុន្មាន?

អ៊ីម : ខ្ញុំកូនពៅគេ ។

ដានី : មីងកាលពីក្មេងៗមានបានរៀនសូត្រដល់ណា?

អ៊ីម : ខ្ញុំអត់បានរៀនផង តាំងពីឆ្នាំ៧០រត់តែគ្រាប់ផ្លោង ហើយយន្តហោះទម្លាក់ អត់ដែលបានរៀនទេ ។

ដានី : អត់បានរៀន?

អ៊ីម : ចា៎!

ដានី : តាំងពីឆ្នាំ៧០មក គ្រាប់ផ្លោង យន្តហោះទម្លាក់?

អ៊ីម : ចា៎! ជួនកាលទាហានឡើងមកផ្លោងរត់ អត់ដែលបានរៀន ។

ដានី : ចេះអាន ចេះសរសេរឥឡូវ?

អ៊ីម : អត់ ស្គាល់អក្សរខ្លះៗ ដោយសារបងអីគាត់ចេះបង្ហាត់ តែគ្រាន់វាអាចរួចខ្លះ អត់ខ្លះ អត់បានរៀន ថាអត់ចេះបណ្តោយ ។

ដានី : ចុះមីងនៅផ្ទះពេលឆ្នាំ៧០នឹង យើងនៅជាមួយឪពុកម្តាយទេ?

អ៊ីម : ចា៎!

ដានី : រត់អីគ្រាប់ផ្លោង គេបាញ់ យើងរត់ជាមួយឪពុកម្ដាយ?

អ៊ុម : ចា៎!

ដានី : នៅជាមួយឪពុកម្ដាយដល់ពេលណាទៅ?

អ៊ុម : ដល់ពេលឆ្នាំ៧៥ ។

ដានី : ឆ្នាំ៧៥ ពេលបែកភ្នំពេញនឹង?

អ៊ុម : ចា៎!

ដានី : បែកភ្នំពេញនឹង យ៉ាងម៉េច មីងចេញពីផ្ទះ?

អ៊ុម : ខ្ញុំនៅ គេហៅកាលនឹងគេហៅកងចល័ត ។

ដានី : បែកភ្នំពេញ គេឲ្យមកនៅកងចល័ត?

អ៊ុម : ចា៎!

ដានី : កងចល័តនៅណាទៅ?

អ៊ុម : កងចល័តនៅស្រុកភ្នំដែក ។

ដានី : នៅស្រុកណា?

អ៊ុម : នៅស្រុកសំរោងទងនឹងដែរ ។

ដានី : នៅស្រុកសំរោងទង ប៉ុន្តែនៅភូមិនេះ នៅកន្លែងណា?

អ៊ុម : នៅភូមិគេហៅស្អី ដើមឫសម៉េច នៅបែកឆ្ងាយដែរនឹង ។

ដានី : ភូមិដើមឫសនៅឆ្ងាយដែរ?

អ៊ុម : ភូមិដើមឫសបែបខេត្តកណ្ដាលតាមមើល ខេត្តកណ្ដាល ។

ដានី : ប៉ុន្តែជិតស្រុកមីងដែរ?

អ៊ុម : ចា៎! ជិតស្រុក ។

ដានី : គ្នាច្រើនគេឲ្យទៅនឹង?

អ៊ុម : ច្រើន គេឲ្យនៅកង នៅរាប់ពាននាក់ ។

ដានី : រាប់ពាននាក់?

អ៊ុម : ចា៎!

ដានី : កាលនឹងមីងអាយុប៉ុន្មានកាលនឹង?

អ៊ុម : ខ្ញុំ៧៥ អាយុ១៥ ។

ដានី : អាយុ១៥ឆ្នាំ?

អ៊ុម : ចា៎!

ដានី : នៅតូចដែរ?

អ៊ុម : ចា៎! គេឲ្យធ្វើអីខ្លះទៅ?

ដានី : វែកដី?

អ៊ុម : ចា៎! វែកដី ហើយជួយច្រូតស្រូវប្រជាជន។

ដានី : កាលនឹងមីង កាលចូលកងចល័តនឹង យើងស្ម័គ្រចិត្ត ឬក៏គេមកជ្រើសរើសឲ្យយើងទៅ?

អ៊ុម : គេជ្រើសរើស គេអត់ឲ្យយើងនៅផ្ទះជាមួយឪពុកម្តាយ ។

ដានី : កាលនឹងមីងទៅចឹង មាននឹកផ្ទះទេ បែកឆ្ងាយចឹង?

អ៊ុម : នឹក អូ! យំកាលនឹង ។

ដានី : យំដែរ?

អ៊ុម : ចា៎! យំ ឲ្យតែដល់ម៉ោងសម្រាក ដូចថាម៉ោងសម្រាកអី ជិតផ្ទះអីនាំគ្នាដើរមកឲ្យបាន ឃើញមុខម៉ែតិចទៅវិញ ដល់ម៉ោងគេ ។

ដានី : ដល់ពេលល្ងាចហើយ?

អ៊ុម : ពេលម៉ោង១១ សម្រាក ។

ដានី : ថ្ងៃ?

អ៊ុម : ចា៎! សម្រាកថ្ងៃ នាំគ្នាដើរផង រត់ផង ឲ្យតែបានឃើញមុខម៉ែម៉ាភ្លែតទៅវិញ ។

ដានី : គេអត់ថាអី?

អ៊ុម : យើងដើរចូលធ្វើការទាន់ម៉ោង អត់អី ។

ដានី : អត់អីទេ?

អ៊ុម : ចា៎!

ដានី : គេអត់ដែលស្តីឲ្យយើង ឬក៏ដាក់ទណ្ឌកម្មអីអត់មាន?

អ៊ុម : កាលពួកខ្ញុំនៅនឹង អត់អីទេ ។

ដានី : អត់អីទេ?

អ៊ុម : ចា៎! បើកន្លែងគេខ្ញុំអត់ដឹង បើថាចំពោះខ្ញុំអត់អីទេ ។

ដានី : ចឹងមីងនៅកន្លែងកងចល័តនៅដើមឫសនឹង ដល់ពេលណាទៅ?

អ៊ុម : ដល់ពេល៧៩ ។

ដានី : នៅកងចល័តនឹងរហូត?

អ៊ុម : ចា៎!

ដានី : អត់មានផ្លាស់ទៅណាមកណា?

អ៊ុម : អត់ ។ ដល់ពេល៧៩ បានខ្ញុំរត់មកដល់ព្រំដែន ។

ដានី : ចឹងនៅកងចល័តនឹងរហូត?

អ៊ុម : ចា៎!

ដានី : ចឹងកាលពីមីងអាយុ១៥ ដល់៧៩ អាយុ១៩?

អ៊ុម : ចា៎!

ដានី : ចឹងគេអត់មានផ្លាស់មីងឲ្យទៅនៅកន្លែងណាទេ? ហើយក៏មានផ្លាស់ទៅនៅណាដែរ?

អ៊ុម : ផ្លាស់ម៉ាភ្លែត រត់បណ្តោយ ។

ដានី : ផ្លាស់ទៅណាម៉ាភ្លែត?

អ៊ុម : ផ្លាស់មកនៅកន្លែង គេហៅសេនាធិការភស្តុភារនេះ ។

ដានី : សេនាភស្តុភារនៅណា នៅភ្នំពេញ?

អ៊ុម : នៅអឺ! កំពង់ស្ពឺ ។

ដានី : នៅកំពង់ស្ពឺ?

អ៊ុម : ចា៎!

ដានី : កាលនឹងក្នុងឆ្នាំ៧៨?

អ៊ុម : ចា៎! នៅដូចថានៅបានកន្លះខែ ក៏រត់មកបណ្តោយ ។

ដានី : ៧៨ គេផ្លាស់មីងឲ្យមកនៅសេនាធិការភស្តុភារនឹង គេឲ្យធ្វើអីទៅ?

អ៊ុម : កាលនឹង គេឲ្យបោសសំរាម បោសអី ដូចថាសំអាតទីធ្លាអីចឹង ។

ដានី : សេនាធិការភស្តុភារនឹងនៅកំពង់ស្ពឺ?

អ៊ុម : ចា៎!

ដានី : សេនាធិការភស្តុភាររបស់អីគេ របស់ភូមិភាគ ឬរបស់តំបន់ ឬអីគេ?

អ៊ុម : ខ្ញុំដូច កាលនឹងដូចម៉េចទេ ដូចរៀនមិនសូវចាំច្បាស់ ដូចថាវារៀងនៅស្ទើរដែរនៅក្មេងដែរ ដល់ពេលមកនៅបានម៉ាតិច រត់យួនបណ្តោយដូចចាំអត់សូវច្បាស់ ថាចាំអត់ច្បាស់ម៉ង ។

ដានី : បានកន្លះខែរត់បណ្តោយ?

អ៊ុម : ចា៎!

ដានី ៖ ដល់ពេលមីងរត់មកយ៉ាងម៉េចទៅ ដល់ពេលយួនចូលមកយើងរត់យ៉ាងម៉េច ម៉េចបាន យើងអត់រត់ទៅផ្ទះ?

អ៊ីម ៖ គេឲ្យយើងមក ។

ដានី ៖ ពីណាគេឲ្យមក?

អ៊ីម ៖ មេធំៗ ប៉ុន្តែខ្ញុំអត់ចាំ គេបេះឲ្យយើងមកច្រើនៗ ទម្លាក់ព្រំដែនបណ្តោយ ។

ដានី ៖ កាលពេលនឹងមីង ដល់ពេលបែកចឹង យើងអត់មានគិតថាយើងរត់ទៅផ្ទះទៅជួបម៉ែឪ?

អ៊ីម ៖ អត់ហ៊ាន ។

ដានី ៖ អត់ហ៊ាន?

អ៊ីម ៖ ចា៎! អត់ហ៊ានទៅ ។

ដានី ៖ អត់ហ៊ានទៅ?

អ៊ីម ៖ ចា៎! ផ្ទះខ្ញុំ ហើយកំពង់ស្ពឺនឹងនៅជិតដែរ ប៉ុន្តែអត់ហ៊ានទៅ ។

ដានី ៖ អត់ហ៊ានទៅ?

អ៊ីម ៖ ចា៎!

ដានី ៖ ចឹងរត់មកដំបូង រត់ពីកំពង់ស្ពឺមកកន្លែងណាទៅ?

អ៊ីម ៖ រត់មក តាមផ្លូវរហូតដល់គេហៅស្អីគេ បរប៉ៃលិន ហើយតាមផ្លូវស្ទឹង ។

ដានី ៖ ស្ទឹងបាត់ដំបង?

អ៊ីម ៖ ចា៎!

ដានី ៖ យូរបានមក?

អ៊ីម ៖ យូរ ។

ដានី ៖ ចុះយើងបានអីហូបទៅតាមផ្លូវ?

អ៊ីម ៖ ហូប ជំនាន់នឹងនៅមានបាយមានអីហូបបណ្តោយ បើដល់ពេល៧៩ នៅតាមព្រំដែននេះមក ហូបបបរម៉ាកំប៉ុង៤នាក់ ។

ដានី ៖ ហូបឆ្អែតអត់?

អ៊ីម ៖ និយាយទៅ បានតែទឹកៗ ។

ដានី ៖ បានតែទឹកៗ ចឹងយើងអត់ហេវ?

អ៊ីម ៖ ដូចថាយើងៗ ដែលចាំជួសក្រោយគេនឹងបានតែទឹកៗ ។

ដានី ៖ ចឹងម៉េចឆ្អែតទៅចឹង?

អ៊ុម : អត់ឆ្អែតទេ ។

ដានី : អត់ឆ្អែតយើងធ្វើម៉េចទៅ?

អ៊ុម : បេះតែទ្រាំរស់ ។

ដានី : យើងអត់មានអីមកហូបបន្ថែមទៀតទេ?

អ៊ុម : អត់ទេ ។

ដានី : កាលនឹងនៅណា?

អ៊ុម : នៅ និយាយទៅនៅតាមជំនៀរព្រំដែន ។

ដានី : ជំនៀរព្រំដែន?

អ៊ុម : ចា៎!

ដានី : ព្រំដែនពីត្រង់ណា?

អ៊ុម : គេហៅអូរអន្លក់ៗនេះ ។

ដានី : អូរអន្លក់?

អ៊ុម : ចា៎!

ដានី : ម្តុំណាអូរអន្លក់?

អ៊ុម : ម្តុំអើយស្រុកកំរៀង កន្លែងឃុំតាសែន អាកន្លែងរង្វង់មូលនេះ ។

ដានី : ឃុំតាសែន?

អ៊ុម : ចា៎! ពួកខ្ញុំនៅម្តុំអស់នេះ ដល់ពេលក្រោយមកបានធ្លាក់ដីថៃ ។

ដានី : ធ្លាក់ដីថៃនៅណា ឆ្នាំណា?

អ៊ុម : ៨៣ ។

ដានី : ៨៣ទៅដីថៃ?

អ៊ុម : ចា៎!

ដានី : ទៅដីថៃនៅណា?

អ៊ុម : នៅនេះ សុតទីលី ។

ដានី : សុតទីលី ម៉េចបានទៅនៅដីថៃ យើងអត់នៅដីយើង?

អ៊ុម : នៅអត់បាន បើយួននៅតាមព្រំដែន ។

ដានី : យួនចូលដល់នឹងដែរ?

អ៊ុម ៖ ចា៎! ដល់កន្លែងនេះ គេហៅផ្លូវពីសន្ដមចាស់ គេហៅផ្លូវព្រៃគុប ហើយដល់ពេលចឹងទៅ នៅដីថៃនឹងនៅមិនបានសុខណា គ្រាប់ប្លោងវត់ មិនដែលបានសុខទេ ។

ដានី ៖ គ្រាប់ប្លោង?

អ៊ុម ៖ ចា៎!

ដានី ៖ យួនប្លោង?

អ៊ុម ៖ ចា៎! ទើបមកផ្ដាច់ខ្លួននេះ បានឡើងមកនៅដីយើង ។

ដានី ៖ កាលនឹងមីងមានចូលធ្វើអីនឹងគេអត់ ពេលដែលយើងនៅតាមព្រំដែន?

អ៊ុម ៖ អត់បានចូលធ្វើអីផង គ្រាន់ដឹកជញ្ជូន ។

ដានី ៖ ហៅកងដឹកជញ្ជូន?

អ៊ុម ៖ ចា៎! កងដឹកជញ្ជូនគ្រាប់រំសេវនេះ ។

ដានី ៖ មីងនៅកងរបស់ពីណាគេ?

អ៊ុម ៖ ខ្ញុំនៅជាមួយពូធីង ។

ដានី ៖ ធីងនឹងគាត់?

អ៊ុម ៖ គាត់នឹងសេនាធិការ ។

ដានី ៖ សេនាធិការកងពលណា?

អ៊ុម ៖ កងពល២៥០ ។

ដានី ៖ កងពល២៥០?

អ៊ុម ៖ ចា៎!

ដានី ៖ ពីណាគេប្រធានកងពល២៥០?

អ៊ុម ៖ អឺ! ពូនី កន ។

ដានី ៖ នី កន?

អ៊ុម ៖ ចា៎!

ដានី ៖ មីងនៅជាមួយពូធីង?

អ៊ុម ៖ ចា៎!

ដានី ៖ នៅខាងដឹកជញ្ជូន?

អ៊ុម ៖ ចា៎!

ដានី ៖ ចុះមីងរៀបការឆ្នាំណា?

អ៊ុម ៖ ខ្ញុំរៀបការឆ្នាំ៨៥ ។

ដានី ៖ កាលនឹងមីងអាយុប៉ុន្មាន?

អ៊ុម ៖ ខ្ញុំអាយុ២៥ ។

ដានី ៖ កាលមីងការអាយុ២៥ ?

អ៊ុម ៖ ចាំ!

ដានី ៖ ប្ដីមីងកាលនឹងគាត់អាយុទើប២០ទេ?

អ៊ុម ៖ ប្ដីខ្ញុំ បើនិយាយទៅ ខ្ញុំប្ដី២ហើយ ។ ប្ដីខ្ញុំមុនគាត់អាយុច្រើនហើយ តែចោរប្លន់ស្លាប់បាត់ហើយ ។ ខ្ញុំយកប្ដីក្រោយបានកូន២ទៀត ។

ដានី ៖ មុនបាន?

អ៊ុម ៖ បានមួយ ប្រុស ។

ដានី ៖ ធំហើយ?

អ៊ុម ៖ មានប្រពន្ធមានកូនហើយ ។

ដានី ៖ មានប្រពន្ធ មានកូន?

អ៊ុម ៖ ចាំ!

ដានី ៖ ចឹងកាល៨៥មីងរៀបការម៉ាសារហើយ?

អ៊ុម ៖ ចាំ!

ដានី ៖ ចឹងគាត់ចោរប្លន់ គាត់ស្លាប់ឆ្នាំណាទៅ?

អ៊ុម ៖ ស្លាប់ ខ្ញុំអត់ចាំ តែចាំថារៀបផ្ដាច់ខ្លួន ។

ដានី ៖ រៀបផ្ដាច់ខ្លួន?

អ៊ុម ៖ ចាំ! រៀបផ្ដាច់ខ្លួននឹង ចោរប្លន់ ។

ដានី ៖ ចោរប្លន់នៅណា?

អ៊ុម ៖ នៅផ្លូវ៦៣០ ។

ដានី ៖ គាត់ទៅណា?

អ៊ុម ៖ គាត់ដែលគេជួលដឹកឈើ កាលនឹងអាត្រាក់រួម មិនមែនអាត្រាក់ឯកជនទេ ប៉ុនចោរប្លន់ ។

ដានី ៖ ចោរប្លន់ ចោរពីខាងណាទៅ?

អ៊ុម ៖ ចោរនឹង បើតាមអ្នករស់និយាយថា ជិះសុំជិះអាត្រាក់ជាមួយ តែមិនដឹងថាចោរនឹងនៅណាយើងអត់ស្គាល់ សុំជិះអាត្រាក់ជាមួយដូចមនុស្សស្គាល់គ្នាចឹង ។

ដានី ៖ ចឹងប្អូនយកអាត្រាក់?

អ៊ុម ៖ ចាំ! ប្អូនៗបាញ់ស្លាប់២នាក់ទៅ យកអាត្រាក់ តែយកអត់បាន អត់ចេះបាត់ អាត្រាក់នឹងបានមកវិញ ។

ដានី ៖ បានលុយកាក់អីដែរ?

អ៊ុម ៖ គាត់ទៅដឹកឈើអត់មានលុយផង វាប្អូន ការពិតទៅលុយនៅក្នុងហោប៉ៅ៣០០ខ្ញុំដាក់ឲ្យអត់យកផង មិនដឹងយ៉ាងម៉េច សម្លាប់មនុស្សចោល ។

ដានី ៖ នៅណា ឆ្ងាយ មីងបានឃើញសពគាត់មក?

អ៊ុម ៖ គេដាក់មក បងប្អូនក្នុងភូមិនឹងដឹកមក ។

ដានី ៖ គាត់ឈ្មោះអីដែរ?

អ៊ុម ៖ ប្តីខ្ញុំមុននឹង?

ដានី ៖ បាទ!

អ៊ុម ៖ ឈ្មោះ ចយ ។

ដានី ៖ ឈ្មោះ ចយ?

អ៊ុម ៖ ចាំ!

ដានី ៖ គាត់អ្នកស្រុកណាដែរ?

អ៊ុម ៖ គាត់នៅអើយ! ខេត្តកណ្តាល ជិតបាត់ដឹង ។

ដានី ៖ ជិតបាត់ដឹង?

អ៊ុម ៖ ចាំ!

ដានី ៖ ខាងអន្លង់ស្នួលអង្គអីនឹង?

អ៊ុម ៖ ចាំ! គាត់នៅនឹង ។

ដានី ៖ ពេលមីងរៀបការក្រោយទៀតឆ្នាំណាទៀត?

អ៊ុម ៖ ខ្ញុំរៀបការក្រោយ ខ្ញុំអត់សូវចាំឆ្នាំទេ ១៩៩៩ ។

ដានី ៖ ៩៩?

អ៊ុម ៖ ចាំ!

ដានី ៖ ដល់ពេលក្រោយមីងបានកូន២នាក់ទៀតនឹង?

អ៊ុម ៖ ២នាក់ មីបងនោះអាយុ១២ហើយ នេះមីប្អូន ។

ដានី ៖ នេះមិនមែនកូនមីងទេ?

អ៊ុម : ចៅ ក្មួយ កូនក្មួយបង្កើត ។

ដានី : កាលនឹងគ្រួសារក្រោយមីង គាត់ធ្វើអីដែរ កាលគាត់រៀបការ គាត់នៅមកតាំងពី៧៩ដូចគ្នា ឬក៏?

អ៊ុម : គាត់នៅស្រុកនោះ តែគាត់មកស៊ីឈ្នួលបើកឡានឲ្យមីងគាត់ ដល់ពេលចឹងទៅគាត់ ។

ដានី : គាត់ឃើញមីងក៏?

អ៊ុម : ចា៎!

ដានី : ចឹងផ្ទះមីងនៅនឹងតាំងពី ដល់ពេលយួនដកចេញទៅ យើងមកវិញ មីងមកនៅនឹងម៉ង ឬក៏យ៉ាងម៉េច?

អ៊ុម : មកដែលនៅ ហើយជាប់ព្រំដែននោះម៉ាសារ ដល់ពេលមកនៅនេះបានម៉ាតិចផ្ដាច់ខ្លួន ។

ដានី : នៅនេះតិចបានផ្ដាច់ខ្លួន?

អ៊ុម : ចា៎! នៅបានប្រហែលម៉ាខែដឹងផ្ដាច់ខ្លួន ។

ដានី : នៅនេះ?

អ៊ុម : ចា៎!

ដានី : កាលនឹង កាលមីងមកនៅនេះ គ្រួសារមីងមុនគាត់នេះនៅ កាលនឹងមីងមកនៅម្នាក់ឯងក៏មីង?

អ៊ុម : អត់ទេ នៅផ្ទះនឹង គាត់ធ្វើតើ ។

ដានី : គាត់ធ្វើទេ?

អ៊ុម : ចា៎! គាត់ធ្វើហើយបានគាត់ស្លាប់ ។

ដានី : ធ្វើហើយបានស្លាប់?

អ៊ុម : ចា៎!

ដានី : ចុះមីងកាលតាំងពីសង្គ្រាមអី មីងអត់ត្រូវរបួសត្រូវអីទេ?

អ៊ុម : ខ្ញុំអត់ត្រូវរបួសទេ តែគ្រាន់ដែលភ្នែកខ្ញុំឈឺ ពិការ ។

ដានី : ភ្នែកនឹងឈឺតាំងពីអន្លាល់?

អ៊ុម : ចា៎! ឈឺកាលខ្ញុំនៅតូច ។

ដានី : តាំងពីតូច?

អ៊ុម : ចា៎!

ដានី : តាំងពីនៅក្មេងៗ នៅស្រុកម៉េច?

អ៊ុម : ចា៎! តាំងខ្ញុំនៅជាមួយម៉ាក់ ។

ដានី : ចុះកាលនឹង កាលពេលមុនផ្តាច់ខ្លួនមានការប្រទាញប្រទុង ប្រទូសប្រទាស់គ្នាដែរ ហើយយ៉ាងម៉េច?

អ៊ុម : អឺ! កាលនឹងដូចម៉េចទេ ផ្តាច់ខ្លួនហើយគេមកគៀបសង្កត់ម៉ាសារទៀត ។

ដានី : អីគេម៉ាសារទៀត?

អ៊ុម : ដូចថាកាលនឹងដូចម៉េចទេ ស្រពេចស្រពិលឃើញរថក្រោះរថអីមកពីខាង...(ស្តាប់មិនបាន) តែខ្ញុំដូចអត់សូវចាំ ។

ដានី : ដល់ពេលយើងផ្តាច់ខ្លួនហើយ យើងយ៉ាងម៉េច ដីធ្លីអីយើងចាប់ យើងធ្វើខ្លួនឯង ឬក៏យើងយ៉ាងម៉េច គេចែកឲ្យ?

អ៊ុម : កាលអត់ទាន់ផ្តាច់ខ្លួននឹង ពូដែលពួកខ្ញុំរស់នៅជាមួយនឹង ខ្មោចពូធីងនឹង គាត់ចែកឲ្យម៉ាគ្រួសារក្បាល៤០ បណ្តោយវែងចឹងទៅ ។

ដានី : នៅក្នុងព្រៃ?

អ៊ុម : ចា៎!

ដានី : បណ្តោយដល់ណាទៅ?

អ៊ុម : បណ្តោយនេះដល់ដើមឈើខ្ពស់មួយ ។ អ្នកណាគេកាប់បានវែងទៅ កាប់បានវែង អ្នកណា ខ្លាចមិនអត់ទៅ អត់ហ៊ានទៅ ។

ដានី : ចឹងមីងកាប់បានវែងដែរ?

អ៊ុម : បានប្រវែងនេះ ។

ដានី : បានប្រវែងនឹង?

អ៊ុម : ចា៎!

ដានី : ហើយមានដីចំការណាផ្សេងទៀត?

អ៊ុម : ដីចំការមានផ្លូវ៣ ។

ដានី : ផ្លូវ៣?

អ៊ុម : ចា៎! មានតែ២កន្លែងនឹងឯង ។

ដានី : ២កន្លែង ចុះកន្លែងណាដាំស្រូវ?

អ៊ុម : ដាំស្រូវនឹងដីប្លង់នេះដែរ ។

ដានី : ប្លង់ខាងក្រោយដល់នោះ?

អ៊ុម ៖ ដីខ្ញុំនៅខាងនោះ អានេះដីគេខ្ញុំនៅកាលក្នុងព្រៃ ដីគេកាលនៅដល់ពេលដាំបានៗហូប ចេញៗទៅនៅឲ្យគេជាប់ផ្លូវដែរ តែខាងនោះ ។

ដានី ៖ ចុះមីងឆ្នាំណាបានទៅលេងផ្ទះវិញ?

អ៊ុម ៖ ខ្ញុំកាលដែលផ្តាច់ខ្លួននឹងខ្ញុំបានទៅម្តង ។

ដានី ៖ ផ្តាច់ខ្លួន?

អ៊ុម ៖ ចា៎! ប្តីដែលគាត់ស្លាប់ទៅនឹងគាត់ទៅ នាំគ្នាទៅផ្ទះនឹង គាត់មកវិញស្លាប់ ។

ដានី ៖ ទៅផ្ទះមីង?

អ៊ុម ៖ ចា៎! ទៅទាំងផ្ទះគាត់ផ្ទះអី ។

ដានី ៖ ទៅទាំង២?

អ៊ុម ៖ ចា៎!

ដានី ៖ ទៅលេងបានប៉ុន្មានថ្ងៃដែរ?

អ៊ុម ៖ ទៅលេង២កន្លែងនឹងបានម៉ាអាទិត្យ ។

ដានី ៖ ២កន្លែងបានម៉ាអាទិត្យ?

អ៊ុម ៖ ចា៎!

ដានី ៖ ហើយមកវិញ ដល់ក្រោយៗទៀត មីងដែលធ្លាប់ទៅលេងផ្ទះទៀតអត់?

អ៊ុម ៖ ខ្ញុំខស្បាហ៍ទៅតើ ពេលម៉ែខ្ញុំឈឺអី ខ្ញុំទៅមើលគាត់ ។

ដានី ៖ ចុះគាត់មានដែលមកលេងមីង?

អ៊ុម ៖ ចុះគាត់មក គាត់នៅតែតិច គាត់នឹកស្រុកកំណើតគាត់ៗទារទៅវិញ ។

ដានី ៖ ចឹង?

អ៊ុម ៖ ចា៎! គាត់ចាស់ហើយ គាត់វង្វេង មកដល់យំមកចឹងទៅ ដល់ពេលយកគាត់មកចឹង គាត់យំទៅវិញ គាត់វង្វេងគាត់ ។

ដានី ៖ ចុះមីងអត់ចង់ទៅនៅស្រុកកំណើតវិញទេ?

អ៊ុម ៖ អត់ៗ បេះនៅ ។

ដានី ៖ អត់បេះនៅ?

អ៊ុម ៖ ចា៎!

ដានី ៖ វាយ៉ាងម៉េច ដូចថាមីងអត់សូវស្គាល់គេ?

អ៊ុម ៖ នៅអត់កើតម៉ង និយាយទៅ ។ ទៅដល់ចង់មកវិញបណ្តោយ អត់បេះ ។

ដានី ៈ យើងអត់មានញាតិមិត្តអីដូចថាគ្រាន់តែមាន?

អុឹម ៈ មាន ប៉ុនសុទ្ធតែបងប្អូន ប៉ុនអត់ចេះនៅ ។

ដានី ៈ ដូចវាអត់សូវស្និតស្នាល ហើយម៉េចបងប្អូន?

អុឹម ៈ ស្និតស្នាលដែរ តែដូចថាយើងមានផ្ទះខ្លួនយើងហើយ ដល់ពេលទៅនៅក្នុងផ្ទះម៉ែមែនដូចបែកចឹង ដូចអត់ចេះនៅ ។

ដានី ៈ ដូចយើងនៅយូរ បែកយូរហើយ?

អុឹម ៈ ចា៎! ពេលនឹកគាត់ចឹងចង់ទៅ ដល់ពេលទៅដល់ចង់មកផ្ទះវិញ ។

ដានី ៈ ទៅហើយចង់មកផ្ទះវិញ?

អុឹម ៈ ចា៎! អត់ចេះនៅ ។

ដានី ៈ អត់ចេះនៅ?

អុឹម ៈ ចា៎! បានតែទៅម៉ាភ្លែតៗ ។

ដានី ៈ ហើយបើនៅនេះអត់អីទេ ញាតិមិត្តជិតខាងរាប់អានគ្នា?

អុឹម ៈ ចា៎! នៅនេះអត់អីធម្មតា ។

ដានី ៈ ចុះកាលតាំង បើតាមមីងវិញ មីងគិតថាមុនសមាហរណកម្ម ក្រោយសមាហរណកម្ម យ៉ាងម៉េចដែរ ខុសគ្នាយ៉ាងម៉េច?

អុឹម ៈ ខុសគ្នា បានច្រើនណាស់ ។

ដានី ៈ ខុសគ្នាបានច្រើន?

អុឹម ៈ ចា៎! បានដូចថាអត់ៗរត់លួនអីចឹងទៅ ហើយបានហូបបានចុកគ្រប់គ្រាន់ មានភ្លើង មានក្តៅមានកង្ហារមានអី បើកាលមុនពិបាកអត់ទាំងភ្លើងអត់ទាំងអីពិបាកវេទនា ។

ដានី ៈ ចុះបាយ ម្ហូប អង្ករ ម្ហូបអាហារមានគ្រប់គ្រាន់ដែរអត់ កាលពីមុន?

អុឹម ៈ ពីមុន កាលនឹងនៅបើកអង្ករហូប ។

ដានី ៈ នៅបើកអង្ករ?

អុឹម ៈ ចា៎! ដល់ពេលក្រោយមកគេប្រឹងរៀងខ្លួនអស់ទៅ អស់អាបើកអាអីនឹង ប្រឹងអ្នកណាប្រឹង បានសៗហូបបានអី អ្នកណាអត់ៗ ។

ដានី ៈ ប៉ុន្តែមីងគិតថាវាស្រួលជាង?

អុឹម ៈ ស្រួល ចង់ឲ្យស្រុកយើងស្រួលរហូត ។

ដានី ៈ ចង់ឲ្យស្រួលរហូត អត់ចង់ឲ្យមានសង្គ្រាមវ៉ៃគ្នាទៀត?

អ៊ីម ៖ អត់ទេ អាណិតកូន វាអត់ដែលជួបប្រទះ ។

ដានី ៖ អត់ដែលជួប?

អ៊ីម ៖ ចា៎! បើខ្ញុំតាំងពីដឹងក្ដីមក មិនដែល ដូចថាបានសុខតិចណា ទើបបានផ្ដាច់ខ្លួននឹង ។ បាន សម័យកសាងម៉ាតិចដែរ ។

ដានី ៖ សម័យកសាង សម័យណា?

អ៊ីម ៖ សម័យកសាងសម័យ ធ្វើកងចល័តនឹង បានម៉ាតិចនឹងឯង មិន៧៩ទៀត ។

ដានី ៖ សម័យកសាង កាលនឹងមីងអត់ពិបាកទេ?

អ៊ីម ៖ ខ្ញុំសម័យកសាងនឹងឯង ខ្ញុំធ្វើកងចល័ត ។

ដានី ៖ បាទ! យើងធ្វើកងចល័ត យើងបានហូបចុកអីគ្រប់គ្រាន់ យើងបានទៅលេងផ្ទះអី?

អ៊ីម ៖ បានទៅលេងផ្ទះម្ដងម្កាលដែរ តែយ៉ាប់ណាស់វែកដី ។

ដានី ៖ វែកដី?

អ៊ីម ៖ ចា៎! វែកដី ចាក់ទំនប់ ជីកព្រែក ។

ដានី ៖ ហត់ទេ ធ្វើការ?

អ៊ីម ៖ ហត់ អឺ! ឡើងស្គមដូចអីចឹង ។

ដានី ៖ ស្គម?

អ៊ីម ៖ ចា៎! វែកដី ។

ដានី ៖ តែសប្បាយអត់?

អ៊ីម ៖ សប្បាយ ។

ដានី ៖ សប្បាយ?

អ៊ីម ៖ ចា៎! គេដាក់មេក្រូ ដាក់អី ។

ដានី ៖ ចុះហូបចុកអីមានបាយទឹកគ្រប់គ្រាន់អត់?

អ៊ីម ៖ ហូបគ្រប់គ្រាន់សម័យនឹង ។

ដានី ៖ ហូបគ្រប់គ្រាន់?

អ៊ីម ៖ ចា៎! បាយម៉ាថ្ងៃ៣ពេល ។

ដានី ៖ ម៉ាថ្ងៃ៣ពេល?

អ៊ីម ៖ ចា៎!

ដានី :	ចុះកាលនឹងគេអត់មានអ្នកកងចល័តជាមួយមីងអីដែរ មានគេចាប់គេអីយកទៅសម្លាប់អីដែរអត់?

អុឹម :	អត់ផង ។

ដានី :	អត់ទេ?

អុឹម :	ចា៎! នៅស្រុកខ្ញុំ អត់ ខ្ញុំអត់ឃើញអត់អីផង តែខ្លាចលរគេផ្សេងម៉េចខ្ញុំអត់ដឹង ។

ដានី :	ចុះប្រធានៗគេ មីងស្គាល់ កាលកងចល័ត?

អុឹម :	ខ្ញុំនិយាយទៅវាភ្លេចអស់ ភ្លេចទាំងឈ្មោះ ភ្លេចទាំងអីអស់ ។

ដានី :	ភ្លេចអស់ហើយ?

អុឹម :	ចា៎! អាយុ១៥ឆ្នាំវាយូរមកហើយ ។

ដានី :	ប៉ុន្តែមីងមានអារម្មណ៍សប្បាយកាលជំនាន់នៅកងចល័ត ហើយម៉េច?

អុឹម :	វានៅក្មេងៗរែកដីដេញគ្នាទៅសប្បាយពេលនឹងទៅ ពេលហត់ទៅ ពេលងើបស្ទូងងើបអីអត់ងងុយអត់អីពិបាកដែរ ។

ដានី :	ងើបស្ទូង ងើបអី?

អុឹម :	ចា៎! ជួនកាលមេគេប្រឡំម៉ោងចឹង ម៉ោង១២យប់ស្ទូងងក់ ។

ដានី :	គេប្រឡំម៉ោង?

អុឹម :	ចា៎! ប្រឡំម៉ោង ម៉ោង១២យប់អី ។

ដានី :	គេដែលធ្វើបាបយើង វ៉ៃយើង?

អុឹម :	អត់ទេ អត់ដែរ ។

ដានី :	មានស្រីៗដែរ ប្រុសៗ?

អុឹម :	ស្រីៗ ។

ដានី :	ចុះឪពុកម្តាយមីងនៅតាមភូមិនឹង គាត់ធ្វើការងារស្រួល ហើយពិបាក?

អុឹម :	កាលជំនាន់នឹង ឪពុកខ្ញុំ គាត់គេឲ្យចិញ្ចឹមមាន់ ។ ហើយម្តាយខ្ញុំគាត់ធ្វើការងារស្ទូងដកតាមសហករណ៍ធម្មតា ។ ឪពុកខ្ញុំគាត់ចិញ្ចឹមមាន់ ធ្វើបន្លែធ្វើអីឲ្យ ។

ដានី :	ចិញ្ចឹមមាន់ ធ្វើបន្លែ?

អុឹម :	ចា៎!

ដានី :	គាត់សុខសប្បាយទាំងអស់គ្នា អត់មានបាត់បង់បងប្អូនទេ កាលសម័យកសាង?

អុឹម :	ចា៎! ខ្ញុំអត់បាត់បង់បងប្អូនទេ ។

ដានី ៖ ចុះមីង ក្រោយនេះឥឡូវនេះ រដ្ឋាភិបាល ហើយនឹងអង្គការសហប្រជាជាតិបានបង្កើតតុលាការមួយដើម្បីជំនុំជម្រះទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងជនទាំងឡាយណាដែល ទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ពី៧៥ដល់៧៩ ។ ហើយរាល់ថ្ងៃនេះ គេកំពុង គេបានជំនុំកាត់ទោសអតីតប្រធានមន្ទីរសន្តិ សុខស-២១ ហៅគុកទួលស្លែងនឹង កាំងហ្គេកអ៊ាវ ហៅឌុចនឹង គេបានជំនុំជម្រះកាត់ទោសគាត់រួចហើយ ។ ហើយខាងមុខទៀតនឹង គេនឹងកាត់ទោសមេដឹកនាំជាន់ខ្ពស់៤រូបទៀត ដែលមាននួន ជា, ខៀវ សំផន, អៀង សារី, និងប្រពន្ធគាត់ គេនឹងប្រហែលជាកាត់ឆាប់ខាងមុខនឹង ។ ចំពោះមីងផ្ទាល់ តាមមីងយល់ឃើញ តាមមីងគិត ការបង្កើតតុលាការដើម្បីកាត់ទោសមេដឹកនាំទាំងអស់នឹង ត្រឹមត្រូវដែរ ឬក៏មិនត្រឹមត្រូវ?

អ៊ុម ៖ ចំពោះខ្ញុំផ្ទាល់ ត្រឹមត្រូវ ។

ដានី ៖ ត្រឹមត្រូវ?

អ៊ុម ៖ ចាំ!

ដានី ៖ ម៉េចបានមីងថាត្រឹមត្រូវ?

អ៊ុម ៖ ចុះបើជំនាន់នឹងវាមិនដឹងថាអ្នកណាអ្នកកាប់សម្លាប់ មិនដឹងច្បាស់ថាមេដឹកនាំណា កាប់សម្លាប់ តែវាមានជំនាន់នឹង ។

ដានី ៖ មាន?

អ៊ុម ៖ ចាំ! ទោះបីក្រុមគ្រួសារខ្ញុំអត់មាន ក៏មានឪពុកក្មេកខ្ញុំប្តីក្រោយនេះ គាត់មាន ។

ដានី ៖ គាត់ត្រូវគេសម្លាប់?

អ៊ុម ៖ ចាំ!

ដានី ៖ ត្រឹមត្រូវមីងថាត្រឹមត្រូវ?

អ៊ុម ៖ ចាំ!

ដានី ៖ ខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំមីងទៀតហើយ ចឹងមីងមានអីចង់បន្ថែមនូវអ្វីដែលខ្ញុំអត់បានសួរនាំមីង?

អ៊ុម ៖ ខ្ញុំមានអីចង់បន្ថែម អត់សូវចេះអក្សរ ការយល់ដឹងតិចណា ខ្ញុំអត់ចេះអក្សរ ។

ដានី ៖ បាទ! ចឹងខ្ញុំអរគុណមីងច្រើន ។

អ៊ុម ៖ ចាំ! អរគុណ ។

«ចប់»